# រក្សាប្រពៃណី

លីណា: លើកដំបូងដែលមីងចាន់គាត់មកឲ្យពេទ្យពិនិត្យបញ្ហារស្បូនរបស់គាត់នោះ គឺកន្លងទៅបានបីបួនឆ្នាំហើយ តែគាត់ខានមកពេទ្យជាយូរយារមកហើយ។ នៅពេលមកជួបពេទ្យម្តងៗគាត់មានការពិបាកណាស់ ព្រោះនៅស្រុកខ្មែរ នៅស្រុកភូមិដែលគាត់រស់នៅ ស្ត្រីតែងតែឲ្យឆ្មបមើលថៃសុខភាពរបស់គេ ហើយបើគ្មានជម្ងឺអ្វីធ្ងន់ធ្ងរទេ គេមិនទៅពេទ្យពិនិត្យជម្ងឺទេ។ មីងចាន់មិនចេះនិយាយភាសាអង់គ្លេស ហើយក៏មិនចេះបើកឡានទៀត ដូច្នេះហើយគាត់មានការពិបាកជាខ្លាំងនៅពេលដែលគាត់ត្រូវការទៅពេទ្យម្តងៗ។ ប៉ុន្តែដោយសារឈឺចាប់មិនបាត់ ទើបគាត់សម្រេចឲ្យក្មួយប្រុសរបស់គាត់ជូនទៅពេទ្យ។

មីងចាន់: សុខសប្បាយឬទេក្មួយ? ក្មួយមកនេះមានការអ្វីដែរ?

សុភា: ខ្ញុំមកឲ្យពេទ្យពិនិត្យសុខភាព ព្រោះខ្ញុំមកពេទ្យនេះរៀងរាល់ឆ្នាំចាប់តាំងពីកូនខ្ញុំកើតម្ល៉េះ ចុះមីងមកនេះមានការអ្វីដែរ?

មីងចាន់: មីងចេះតែឈឺពោះ

លីណា: ថ្ងៃនោះត្រូវថ្ងៃមីងយ៉ានមកពិនិត្យរោគដែរ ម្តាយរបស់មីងយ៉ានទើបតែស្លាប់ដោយកើតរោគមហារីកស្បូន មីងយ៉ានបានតឿនម្តាយរបស់គាត់ឲ្យទៅពេទ្យនៅពេលដែលគាត់ទើបតែចាប់ផ្តើមឈឺ ប៉ុន្តែម្តាយរបស់គាត់ចេះតែបង្អង់យូររហូតទាល់តែហួសពេលមើលមិនជា។

គ្រូពេទ្យ: សួស្តីលោកស្រីយ៉ាន ខ្ញុំមិនបានជួបអ្នកជាយូរមកហើយ តើលោកស្រីមានការអ្វីដែរ?

ចិត្តនា: សុខសប្បាយឬទេមីង? ខ្ញុំខានឃើញមីងយូរហើយ តើមីងអញ្ជើញមកនេះមានការអ្វីដែរ?

មីងយ៉ាន: កន្លងមកនេះខ្ញុំគិតច្រើនណាស់ ញ៉ាំក៏មិនបានចេះតែឈឺក្បាល ហើយគេងក៏មិនលក់ នៅសប្តាហ៍ខាងមុខនេះ និងដល់បុណ្យខួបមួយរយថ្ងៃតាំងតែពីម្តាយខ្ញុំបានស្លាប់ទៅ។

លីណា: មីងយ៉ានព្រួយចិត្តខ្លាំងណាស់ ព្រោះគាត់ខ្លាចកើតជម្ងឺដូចម្តាយរបស់គាត់ដែរ គ្រូពេទ្យ Drew បានធ្វើតែស្តនិងរកមើលជម្ងឺមហារីកស្បូនជូនគាត់ហើយ នៅថ្ងៃនោះគ្រូពេទ្យបានជំរាបគាត់ថាអ្នកមីងយ៉ានមិនកើតជម្ងឺមហារីកស្បូនទេ ហើយគាត់មានសុខភាពល្អប្រសើរ។ គ្រូពេទ្យបានពន្យល់ប្រាប់អ្នកមីងយ៉ានថា ការដែលគាត់ពិបាកចិត្តគេងមិនលក់នោះ គឺជាការធម្មតាទេ ព្រោះម្តាយរបស់គាត់ទើបតែស្លាប់ថ្មីៗ។ លោកគ្រូពេទ្យមានការព្រួយបារម្ភចំពោះមីងយ៉ានណាស់ គាត់បានប្រាប់មីងយ៉ានឲ្យត្រឡប់មកកាន់មន្ទីរពេទ្យវិញ បើមីងមិនបានស្រួលខ្លួននៅឡើយ។

លីណា: ដល់វេនមីងចាន់ត្រូវជួបជាមួយនឹងគ្រូពេទ្យម្តង មីងចាន់មានការខ្មាស់អៀនណាស់នៅពេលដែល គាត់បានឃើញគ្រូពេទ្យប្រុសហើយនិងអ្នកបកប្រែភាសាជាមនុស្សប្រុស។

គ្រូពេទ្យ: សួស្តីលោកស្រីចាន់ ខ្ញុំរីករាយណាស់ដែលបានជួបអ្នក តើអ្នកកើតអ្វីដែរ?

ដារា: សួស្តីមីង មីងសុខសប្បាយជាទេ? តើមីងកើតអ្វីដែរថ្ងៃនេះ?

មីងចាន់: (មីងចាន់យកដៃមួយទប់ពោះ ហើយដៃម្ខាងទៀតចង្អុលទៅជង្គង់គាត់) ខ្ញុំឈឺជង្គង់លោកពេទ្យ។

ដារា: ជង្គង់គាត់ឈឺ

គ្រូពេទ្យ: តើជង្គង់មីងឈឺយូរហើយឬ?

ដារា: តើជង្គង់មីងឈឺយូរហើយឬ?

លីណា: មីងចាន់គាត់អៀនខ្មាស់យ៉ាងខ្លាំងរហូតទាល់មិនហ៊ានប្រាប់ពេទ្យប្រុសនោះថា គាត់មានបញ្ហាសួន ហើយបែជាប្រាប់ថាគាត់ឈឺជង្គង់ទៅវិញ ព្រោះគាត់ខ្លាចគ្រូពេទ្យពិនិត្យសួនរបស់គាត់។

ចិត្តនា: មីង! សុខសប្បាយជាឬទេមីង?

មីងចាន់: ចាស៎! (ធ្វើអេះអុញមិនចង់ឆ្លើយ) ខ្ញុំសុំសួរបន្តិចសិនក្មួយ?

ចិត្តនា: ចាស៎! ខ្ញុំនិងទៅជួបមីង។

ដារា: ជាការប្រសើរណាស់ដែលបានជួបមីង ខ្ញុំសង្ឃឹមថាជង្គង់របស់មីងនឹងបានជា។

លីណា: មីងចាន់បានដំណាលរឿងសម្ងាត់របស់គាត់ប្រាប់ទៅចិត្តនាថាគាត់ឈឺពោះ ហើយគាត់ខ្លាចមាន បញ្ហាសួន ប៉ុន្តែគាត់មិនហ៊ានប្រាប់គ្រូពេទ្យដោយគាត់មានការអៀនខ្មាស់ខ្លាំងពេកនៅពេលដែល គាត់បានឃើញពេទ្យប្រុសនិងអ្នកបកប្រែប្រុសមកជួបគាត់ ហើយគាត់មិនដឹងជាត្រូវធ្វើយ៉ាងណាទេ ពេលនោះចិត្តនាបានប្រាប់គាត់វិញថា មីងចាន់អាចធ្វើការណាត់ជួបជាមួយពេទ្យស្រីបាន។ លុះថ្ងៃ បន្តិច ចិត្តនានឹងទៅជួបមីងចាន់នៅឯផ្ទះរបស់គាត់ជាមួយមារីអ្នកដែលទើបចូលធ្វើការថ្មី។

លីណា: មុនដំបូងចិត្តនានិងមារីទៅសួរសុខទុក្ខស្ត្រីដែលទើបតែសំរាលកូនហើយ។ មីងវីជាម្តាយក្មេក របស់នាងដែលទើបតែសំរាលកូនហើយ។ មីងវីកាន់ទំនៀមទម្លាប់ខ្មែរបានល្អណាស់ ហើយគាត់

ចង់ឲ្យកូនប្រសាររបស់គាត់ថែខ្លួនអោយមានសុខភាពល្អនៅពេលដែលនាងកំពុងតែមានសរសៃខ្ចី។ តែកូនប្រសារមីងវីចូលចិត្តធ្វើតាមរបៀបអាមេរិកាំង។ មីងវីមានជំនឿរថា បើស្ត្រីមិនថែខ្លួនឲ្យបានល្អនៅកម្លុងពេលសរសៃខ្ចីទេ ដល់យូរទៅមុខទៀត នឹងមានជម្ងឺស្បូនធ្វើទុក្ខ។

មីងវីៈ សុខសប្បាយជាទេនាង ចូលមកក្នុងផ្ទះមកមើលកូនងាំ ពេលមើលរួចហើយមកជួបជុំគ្នានៅកន្លែងនេះណា។

មីងវីៈ ក្មេងអស់នេះមិនចូលចិត្តធ្វើតាមទំនៀមទម្លាប់ខ្មែរទេ។

ផល្លីៈ មីង! នៅប្រទេសនេះមានម្ហូបឆ្ងាញ់ៗ ហើយក៏មានថ្នាំពេទ្យល្អៗ ពេលឈឺទៅឲ្យពេទ្យពិនិត្យមើលជម្ងឺទៅ។

ដារីៈ ពេលទៅជួបពេទ្យនៅស្រុកនេះ គ្រូពេទ្យមិនបានប្រាប់អោយកាន់ទម្លាប់ខ្មែរ ឬអោយថែសរសៃខ្ចីអ្វីផង។ ហើយចុះចំណែកស្ត្រីអាមេរិកាំងវិញ គ្រូពេទ្យមិនបានប្រាប់គេអោយធ្វើតាមទម្លាប់ខ្មែរទេ។

មីងវីៈ ចាស៎! ដារីឯងដឹងទេ តើស្ត្រីអាមេរិកាំងមានជម្ងឺស្បូនធ្វើទុក្ខច្រើនប៉ុន្មានដែរ? នោះចិត្តនាមកហើយ សាកសួរមើលទៅ!

ចិត្តនាៈ ថាអញ្ចឹងក៏បានដែរ ព្រោះស្ត្រីអាមេរិកាំងទៅពេទ្យពិនិត្យសុខភាពរៀងរាល់កំណត់ពេលដែលត្រូវទៅ ទោះបីជាគេមិនឈឺក៏ទៅដែរ គ្រូពេទ្យអាចជួយបានបើរកឃើញពេលជម្ងឺទើបតែចាប់ផ្តើម។ ខ្ញុំនឹកឃើញពេលនៅជុំរុំ មានមីងម្នាក់នោះកើតដំបៅស្បូន គ្រូពេទ្យថាគាត់ទុកយូរពេករហូតទាល់តែមិនអាចព្យាបាលបាន គួរឲ្យអាណោចអាធម្មណាស់ដែលគាត់មិនបានរស់នៅថែកូន។

លីណាៈ ចិត្តនាបានពន្យល់ដល់ស្ត្រីទាំងនោះថា នៅប្រទេសអាមេរិក គ្រូពេទ្យធ្វើផែបតែស្ត (Pap Test) ដើម្បីរកមើលជម្ងឺដូចជាដំបៅស្បូនឲ្យបានឃើញទាន់ពេល វាងាយស្រួលក្នុងការព្យាបាល ម្យ៉ាងវិញទៀតមិនបាច់កាត់ស្បូនចេញ ហើយការធ្វើផែបតែស្តនេះបានជួយទុកជីវិតស្ត្រីជាច្រើននាក់។

ចិត្តនាៈ នៅស្រុកខ្មែរយើងមិនមានការធ្វើផែបតែស្តដើម្បីរកមើលជម្ងឺនៅក្នុងស្បូនទេ គឺមានតែឆ្មបបង្រៀនឲ្យធ្វើតាមទំនៀមទម្លាប់ខ្មែរប៉ុណ្ណោះ។ នៅស្រុកខ្មែរយាយរបស់មារីធ្លាប់ធ្វើឆ្មប ហើយគាត់បានជួយស្ត្រីជាច្រើនឆ្លងទន្លេ។

មារីៈ ចាស៎! គេហៅយាយខ្ញុំថា "អ្នកចម្លងទូក" ដូច្នេះយើងអាចថែសុខភាពរបស់យើងតាមរបៀបខ្មែរផង និងតាមរបៀបអាមេរិកាំងផង។

មីងវី:	ទៅឲ្យពេទ្យមើលស្បូន ងាប់ហើយខ្ញុំខ្មាស់គេណាស់នាង!

ឆាយ:	ទៅឲ្យពេទ្យពិនិត្យ ខ្ញុំខ្មាស់ពេទ្យណាស់ ជាពិសេសពេទ្យប្រុស។

ចិត្តនា:	ចាស់ខ្ញុំដឹងថាគួរឲ្យខ្មាស់អៀនណាស់ ប៉ុន្តែអ៊ុំអាចសួររកពេទ្យស្រីនៅពេលដែលអ៊ុំដាក់ពាក្យណាត់ជួបពេទ្យ។

មីងវី:	ចុះស្ត្រីខ្លះទៀតមិនបាច់ទៅពេទ្យមើលស្បូនទេឬអ្វី? តើគេហៅថាអីទៅផែបតែស្តហ្នឹង? មានស្ត្រីច្រើនណាស់ដែលធ្វើតាមទម្លាប់ខ្មែរយើង។

ចិត្តនា:	របៀបថៃទាំសរសៃខ្ចីសំរាប់ការពារស្បូនមិនគ្រប់គ្រាន់ទេ ការធ្វើផែបតែស្តអាចរកឃើញជម្ងឺដែលកើតឡើងនៅក្នុងស្បូនដែលយើងមើលមិនឃើញ ដូច្នេះស្ត្រីខ្មែរត្រូវថៃខ្លួននៅពេលសរសៃខ្ចីហើយត្រូវធ្វើផែបតែស្តផង។

សីហា:	ចំពោះស្ត្រីខ្លះៗដែលមានវយ័ចំណាស់ព្រមទាំងគ្មានប្តីផង ហេតុអ្វីបានត្រូវធ្វើផែបតែស្តដែរ?

ចិត្តនា:	ស្ត្រីយើងគួរឲ្យពេទ្យពិនិត្យស្បូនអោយបានទៀងទាត់ មិនថាស្ត្រីនោះមានប្តីឬអត់ប្តីទេ ម្យ៉ាងវិញទៀត ទោះបីស្ត្រីនោះចាស់ឬក្មេង មានជម្ងឺឬគ្មានជម្ងឺអ្វី ក៏គួរអោយពេទ្យធ្វើផែបតែស្តឲ្យបានទៀងទាត់ដែរ។

ដារី:	គ្រូពេទ្យខ្ញុំបានពិនិត្យស្បូនឲ្យខ្ញុំនៅពេលដែលខ្ញុំមានផ្ទៃពោះ កាលនោះមិនដឹងជាខ្ញុំបានធ្វើផែបតែស្តដែរឬអត់?

មារី:	ចំពោះស្ត្រីក្មេងគ្រូពេទ្យបានធ្វើផែបតែស្តឲ្យនៅពេលដែលមានផ្ទៃពោះ តែតាមធម្មតាគ្រូពេទ្យមិនធ្វើផែបតែស្តនៅពេលពិនិត្យស្បូនទេ ដូច្នេះហើយអ្នកត្រូវតែសួរបញ្ជាក់នឹងគ្រូពេទ្យរបស់អ្នក។

លីណា:	មារីបានរៀបរាប់ពីភាពខុសគ្នាក្នុងការមើលស្បូននិងការធ្វើផែបតែស្ត។ ការពិនិត្យស្បូនគឺគ្រូពេទ្យពិនិត្យមើលខាងក្នុងស្បូន រកមើលជម្ងឺអ្វីដែលខុសប្លែកពីធម្មតា។ ឯផែបតែស្តវិញនិងជួយរកជម្ងឺផ្សេងៗនៅក្នុងស្បូន។

ដារី:	ខ្ញុំឲ្យពេទ្យមើលស្បូនរួចហើយ ប៉ុន្តែមិនដឹងជាពេទ្យបានធ្វើផែបតែស្តឲ្យខ្ញុំដែរឬអត់ តើគេប្រើប្រដាប់ម្យ៉ាងមានរៀងដូចចំពុះទាហ្នឹងឬ?

មារី: ប្រដាប់នោះហៅថាស្ពិកយ្យូឡុម (Speculum) គ្រូពេទ្យប្រើប្រដាប់នោះស៊កចូលទៅក្នុងស្បូន នៅពេលធ្វើផែបតែស្តនិងនៅពេលពិនិត្យស្បូន។ ខ្ញុំនឹងបង្ហាញជូនអំពីគ្រឿងប្រដាប់ប្រដារដែលពេទ្យប្រើ។

លីណា: ចិត្តនាបានពន្យល់ប្រាប់នៅពេលធ្វើផែបតែស្ត ពេទ្យនឹងយក ស្ពិកយ្យូឡុម (Speculum) ស៊កចូលក្នុងមាត់ស្បូន រួចពេទ្យយកបន្ទះតូចមួយកោសសាច់សើរៗនៅលើមាត់ស្បូន រួចហើយយកកោសិកានោះដាក់នៅលើកញ្ចក់តូចមួយ ហើយយកទៅមន្ទីរពិសោធន៍ រួចពេទ្យនឹងពិនិត្យមើលតាមកែវឆ្លុះ ប្រហែលរយៈពេលបីឬបួនអាទិត្យក្រោយមក ទើបដឹងអំពីលទ្ធផលនៃការពិនិត្យ។ ការធ្វើតែស្តនេះមិនមានការឈឺចាប់អ្វីទេ ហើយក៏គ្មានគ្រោះថ្នាក់ដល់ស្បូនដែរ។

លីណា: បន្ទាប់ពីពន្យល់ប្រាប់អំពីផែបតែស្តដល់ស្ត្រីទាំងនោះរួចហើយ មារីនិងចិត្តនាសុំលាស្ត្រីទាំងនោះដើម្បីទៅជួបមីងចាន់។

ចិត្តនា: សុខសប្បាយជាទេសុភា តើសុភាឯងបានជួបមីងចាន់ឬទេក្នុងថ្ងៃនេះ?

សុភា: ចាស៎! គាត់ឥឡូវនេះប្រហែលនៅក្នុងសួនច្បារខាងក្រោ គាត់ប្រាប់ខ្ញុំថាបងមកជួបគាត់។

លីណា: សុភាជាស្ត្រីម្នាក់ដែលរវល់យ៉ាងមមាញឹកដូចជាស្ត្រីខ្មែរឯទៀតដែរ នាងនៅធ្វើតាមទម្លាប់ខ្មែរ ហើយថែមទាំងជួយបង្រៀនក្មេងឲ្យរាំរបាំខ្មែរផង។ នាងបានរៀនអំពីការរស់នៅជារបៀបអាមេរិកាំង ដោយនាងមានឡានហើយតែងតែជួយដឹកស្ត្រីឯទៀតទៅពិនិត្យរោគនៅមន្ទីរពេទ្យ។

ចិត្តនា: ខ្ញុំបានឃើញសុភាឯងថ្ងៃនេះ តើសុភាមានសុខភាពល្អធម្មតាទេឬ?

សុភា: ចាស៎! ខ្ញុំទៅឲ្យពេទ្យធ្វើផែបតែស្តទេតើ។

លីណា: សុភាប្រាប់ចិត្តនានិងមារីថាគេទៅពេទ្យធ្វើផែបតែស្ត ព្រោះជាការចាំបាច់សំរាប់ស្ត្រីខ្មែរក្នុងការថែរក្សាស្បូន។ សុភាគ្មានជម្ងឺស្បូនធ្វើទុក្ខទេ នាងបានទៅជួបពេទ្យធ្វើផែបតែស្តបានទៀងទាត់ ដូច្នេះហើយបើសិនជាមានជម្ងឺមហារីកចាប់ផ្តើមកើត គ្រូពេទ្យនាងអាចជួយនាងបាន។

សុភា: ការថែរក្សាគ្រួសារជាភារកិច្ចមួយដ៏សំខាន់ណាស់ ហើយកូនរបស់ខ្ញុំក៏ត្រូវការខ្ញុំណាស់ដែរ។

មារី: ត្រូវហើយការធ្វើផែបតែស្តជាការប្រសើរណាស់សំរាប់ការថែសុខភាពរបស់យើង។

សុភា: នៅស្រុកខ្មែរមានគ្រូខ្មែរនិងឆ្មបសំរាប់ជួយមើលជម្ងឺ នៅប្រទេសនេះ យើងគ្មានគ្រូខ្មែរនិងឆ្មបសំរាប់ជួយមើលជម្ងឺឲ្យយើងទេ គឺយើងមានតែទៅឲ្យគ្រូពេទ្យធ្វើផែបតែស្ដអោយយើងនឹងហើយ។ ម្លោះហើយយើងត្រូវធ្វើតាមរបៀបខ្មែរនិងរបៀបអាមេរិកកាំងផង។

លីណា: សុភាតែងតែបើកឡានជូនស្រ្ដីឯទៀតទៅធ្វើផែបតែស្ដ នេះជាវិធីមួយរបស់សុភា។ ហើយពេលដែលសុភាទៅពេទ្យ ស្រ្ដីទាំងនោះជួយមើលកូនឲ្យសុភាវិញ។

ចិត្តនា: ខ្ញុំរីករាយណាស់ដែលបានជួបនិងសុភា ឥឡូវខ្ញុំទៅរកមីងចាន់សិន។

លីណា: ចិត្តនាបានសួរសុខទុក្ខមីងចាន់រួចហើយ ក៏លាតរូបភាពបង្ហាញអំពីសុដនដែលកើតជម្ងឺ បណ្ដាលឲ្យរាលដាលដូចជាគ្រាប់ផ្កាអញ្ចឹង វាចាប់ផ្ដើមឡើងដូចជាគ្រាប់ផ្កាដុះកប់នៅក្នុងដី បើយើងមើលនឹងភ្នែកទទេ មើលមិនឃើញគ្រាប់ផ្កានោះទេ។

នៅពេលដែលសុដនចាប់ផ្ដើមបង្ករជាជម្ងឺ យើងមើលនឹងភ្នែកទទេមើលមិនឃើញទេ នៅពេលដែលមហារីកសុដននេះកើតឡើងហើយបើទុកវាមិនឲ្យពេទ្យព្យាបាលទេ វានឹងដុះរីកកាន់តែធំហើយក្លាយទៅជាដំបៅ។ ដំបៅនោះនឹងក្លាយទៅជាទុំ ទោះបីមិនមានកើតជម្ងឺធ្លាក់សុដនក៏ដោយ។

ចិត្តនា: មីងឃើញទេ ការធ្វើផែបតែស្ដអាចរកឃើញគ្រាប់មហារីកមុន បើវាមានមែន ពេទ្យនឹងវះកាត់គ្រាប់នោះចេញមុននិងវាចាប់ផ្ដើមដុះ។

មីងចាន់: សួនច្បារនិមួយៗតែងតែមានស្មៅ តើសុដនរបស់ស្រ្ដីគ្រប់ៗគ្នានោះសុទ្ធតែមានមហារីកឬ?

មារី: មីង! មិនមែនបានន័យថាសុដនទាំងអស់សុទ្ធតែកើតមហារីកនោះទេ ប៉ុន្តែគ្មានអ្នកណាម្នាក់ដឹងថាស្រ្ដីណាមួយមានមហារីកទេ ដូច្នេះហើយបានពេទ្យត្រូវធ្វើការពិនិត្យជម្ងឺនេះគ្រប់ៗគ្នា។

ចិត្តនា: ដូចបោចស្មៅនៅក្នុងសួនច្បារអញ្ចឹង ការធ្វើផែបតែស្ដនេះត្រូវធ្វើឲ្យបានទៀងទាត់ មិនមែនធ្វើតែម្ដងទេ។ បើមីងធ្វើតែស្ដបានទៀងទាត់ហើយមានជម្ងឺមហារីក គ្រូពេទ្យអាចរកវាឃើញនៅថ្មីៗ ហើយវាក៏មិនទាន់យឺតពេលសំរាប់ព្យាបាល។

មារី: មីង! មីងថែសួនច្បាររបស់មីងបានល្អណាស់ ឥឡូវនេះដល់ពេលដែលមីងថែសុខភាពរបស់មីងម្ដង។

លីណា: ដំណើររឿងយើងបានចាប់ផ្ដើមតាំងពីបីបួនឆ្នាំមុន មីងចាន់ឥឡូវនេះមកធ្វើផែបតែស្ដយ៉ាងទៀងទាត់។ កាលលើកមុនដែលគាត់មានបញ្ហារសុដននោះ គ្រូពេទ្យបានព្យាបាលឲ្យគាត់រួចហើយ

គាត់មានសុខភាពល្អធម្មតាទេ។ ចំណែកចិត្តនាវិញនាងនៅបន្តរជួយធ្វើការណាត់ឲ្យមីងចាន់ទៅជួបពេទ្យស្រីពេលដែលគាត់ទៅពិនិត្យសួនបែបផែបស្បៀរ។

មីងចាន់: សូភា! ខ្ញុំបានឮអំពីក្រុមសិល្បៈខ្មែររបស់សូភាហើយ។ តើសូភាមកធ្វើអ្វីដែរហ្នឹង?

សូភា: ខ្ញុំមកទីនេះឲ្យពេទ្យធ្វើផែបស្បៀរឲ្យខ្ញុំ ហើយចុះម្ដេចមីងមកទីនេះដែរ?

មីងចាន់: ខ្ញុំមកឲ្យពេទ្យធ្វើផែបស្បៀរឲ្យដែរ ហើយគ្រូពេទ្យខ្ញុំឈ្មោះចិន្ទី។ ចុះសូភាឯងជួបគ្រូពេទ្យមួយណាដែរ?

សូភា: ខ្ញុំនឹងជួបពេទ្យប្រុសឈ្មោះដាវិដ គាត់បានជួយមើលជម្ងឺខ្ញុំយូរហើយ ហើយគាត់បានជួយខ្ញុំច្រើនណាស់។

លីណា: រឿងរបស់យើងសូមចប់ត្រឹមនេះសិន ប៉ុន្តែស្ត្រីទាំងនេះសូមផ្ដាំរំលឹកដល់ស្ត្រីទាំងអស់ដែលមានអាយុលើសពី១៨ឆ្នាំ ត្រូវទៅឲ្យពេទ្យធ្វើផែបតែស្តអោយបានទៀងទាត់ ព្រោះយើងមិនអាចដឹងថា ស្ត្រីណាមួយចាប់ផ្តើមកើតជម្ងឺមហារីកមុនគេទេ។ ដូច្នេះហើយ ទោះបីជាអ្នកមានបញ្ហាសួនឬគ្មានបញ្ហានេះក៏ដោយ ក៏ត្រូវធ្វើផែបតែស្ត។ ទោះបីជាអ្នកមានប្តីឬអត់មានប្តី ត្រូវធ្វើផែបតែស្ត។ ទោះបីជាអ្នកមានកូនឬអស់រដូវ ត្រូវធ្វើផែបតែស្ត។ ទោះបីជាអ្នកក្មេងឬចាស់ ត្រូវធ្វើផែបតែស្ត។

ការធ្វើផែបតែស្តនេះ គឺជាការថែទាំសុខភាពយើងតាមរបៀបថ្មីដែលយើងមិនមានពីមុនមក។ ចូរចាំថា៖ យើងអាចថែរក្សាខ្លួនយើងដោយធ្វើតាមរបៀបខ្មែរផង និងតាមរបៀបអាមេរិកាំងផង។